# សុន្ទរកថារបស់លោក យូណាមីណិ ម៉ូរីយ៉ាស៊ុ
# លេខាទី២ នៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# ថ្លែងក្នុងពិធីប្រគល់-ទទួលបរិក្ខារពេទ្យ
# នៅមន្ទីរពេទ្យបង្អែកពារាំង ខេត្តព្រៃវែង
# ថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០១៤

សូមគោរព ឯកឧត្តមវេជ្ជបណ្ឌិត ម៉ៅ តាំងអ៊ាង ប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន (CENAT)
សូមគោរព លោកវេជ្ជបណ្ឌិត អ៊ុង ចាន់ជឿន អនុប្រធានមន្ទីរសុខាភិបាលខេត្តព្រៃវែង
សូមគោរព លោក ហ៊ី ធួក អភិបាលនៃគណៈអភិបាលស្រុកពារាំង ខេត្តព្រៃវែង
សូមគោរព លោកវេជ្ជបណ្ឌិត ហ៊ួត កល្យាណ ប្រធានស្រុកប្រតិបត្តិពារាំង ខេត្តព្រៃវែង
សូមគោរព លោកវេជ្ជបណ្ឌិត អ៊ុំ សារិទ្ធ ប្រធាន មន្ទីរពេទ្យបង្អែកពារាំង
សូមគោរព លោកវេជ្ជបណ្ឌិត អូកាដា កូសុកិប្រធានអង្គការចាតាប្រចាំកម្ពុជា
សូមគោរព លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់

ខ្ញុំមានសេចក្ដីសោមនស្សរីករាយក្រៃលែងដែលបានចូលរួមក្នុង ពិធី ប្រគល់ - ទទួលបរិក្ខារពេទ្យ រួមមានប្រព័ន្ធឆ្លុះកាំរស្មីអ៊ិចឌីជីថល មីក្រូទស្សន៍ហ្វុយអូរ៉េសង់ដែលផ្ដល់សម្រាប់គម្រោងពង្រឹងសមត្ថភាពការធ្វើរោគវិនិច្ឆ័យជំងឺរបេងនៅមន្ទីរពេទ្យបង្អែកស្រុកពារាំង ខេត្តព្រៃវែងក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមវេជ្ជបណ្ឌិត ម៉ៅ តាំងអ៊ាង**ប្រធានមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន។ ជាបឋមខ្ញុំសូមសំដែងនូវការដឹងគុណដ៏ជ្រាលជ្រៅដល់មន្ទីរពេទ្យបង្អែក និងប្រជាជនស្រុកពារាំងដែលបានរៀបចំឲ្យមានពិធីនេះឡើង។

វិស័យសុខាភិបាលគឺជាវិស័យអាទិភាពមួយនៃជំនួយឥតសំណងរបស់ជប៉ុនចំពោះប្រទេសកម្ពុជា ហើយរដ្ឋាភិបាលជប៉ុនបាននិងកំពុងជួយយ៉ាងសកម្មដល់វិស័យនេះតាមរយៈការសាងសង់អគារមន្ទីរពេទ្យ និងគ្លីនិកនិងតាមរយៈការផ្ដល់វគ្គបណ្ដុះបណ្ដាលជាដើម។

ខ្ញុំបានដឹងថាបរិក្ខារពេទ្យដែលប្រគល់-ទទួលនៅថ្ងៃនេះមានប្រសិទ្ធិភាពខ្ពស់ក្នុងការធ្វើវិភាគបានលឿននូវមេរោគរបេង។ យើងក៏រំពឹងដែរថាគម្រោងនេះនឹងជួយរួមចំណែកក្នុងការកាត់បន្ថយនូវអត្រាឆ្លងរោគរបេងនៅប្រទេសកម្ពុជា ហើយគម្រោងនេះនឹងនាំមកនូវសុខភាពល្អសម្រាប់ប្រជាជនកម្ពុជា។

ខ្ញុំសង្ឃឹមថាបរិក្ខារពេទ្យដែលផ្ដល់ជូនតាមរយៈគម្រោងនេះនឹងត្រូវបានថែរក្សាយ៉ាងល្អដើម្បីឲ្យប្រជាពលរដ្ឋអាចទទួលផលប្រយោជន៍ពីគម្រោងនេះបានកាន់តែច្រើន។

ជាទីបញ្ចប់ ខ្ញុំជឿជាក់ថាគម្រោងនេះនឹងជួយពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនកម្ពុជានិងប្រជាជនជប៉ុន។

សូមអរគុណច្រើន។